# សិក្ខាសាលាផ្សព្វផ្សាយ

## ស្តីពី

## « កាតព្វកិច្ចគណនេយ្យនិងសវនកម្ម សម្រាប់អង្គភាពមិនស្វែងរកប្រាក់ចំណេញ និង ស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិលេខ ១៨ »

ថ្ងៃទី ១១ ខែកក្កដា ឆ្នាំ ២០២៤ ម៉ោង ៨:០០ ព្រឹក ដល់ ១២:០០ ថ្ងៃត្រង់

ទីកន្លែង៖ ភោជនីយដ្ឋានទន្លេបាសាក់ II រាជធានីភ្នំពេញ

### ១.បរិបទ

ច្បាប់ស្តីពីគណនេយ្យ និងសវនកម្មត្រូវបានអនុម័ត និងប្រកាសឱ្យប្រើប្រាស់នៅព្រះរាជណាចក្រកម្ពុជាក្នុងឆ្នាំ២០១៦។ ច្បាប់នេះបង្កើតឡើងក្នុងគោលបំណងគ្រប់គ្រងវិស័យគណនេយ្យ និងសវនកម្មប្រកបដោយប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព និងជំនឿទុកចិត្ត។ ច្បាប់នេះមានវិសាលភាពអនុវត្តចំពោះស្ថាប័នសាធារណ: សហគ្រាស អង្គភាពមិនស្វែងរកប្រាក់ចំណេញ គណនេយ្យករ និងសវនករ ប៉ុន្តែមិនអនុវត្តចំពោះធនាគារកណ្តាល និងចំពោះតួនាទី និងភារកិច្ចដែលជាសមត្ថកិច្ចរបស់អាជ្ញាធរសវនកម្មជាតិនោះទេ ។

ច្បាប់នេះដាក់បញ្ចូលនូវកាតព្វកិច្ចមួយចំនួន ដែលកំណត់ឱ្យអង្គភាពមិនស្វែងរកប្រាក់ចំណេញ ត្រូវអនុវត្ត ដែលក្នុងនោះមានដូចជា **កាតព្វកិច្ចរក្សាកំណត់ត្រាហិរញ្ញវត្ថុឱ្យបានត្រឹមត្រូវ រៀបចំរបាយការណ៍ហិរញ្ញវត្ថុឱ្យរងសវនករឯករាជ្យ និងរៀបចំបញ្ជូនរបាយការណ៍ហិរញ្ញវត្ថុទៅកាន់និយ័តករគណនេយ្យ និងសវនកម្ម** ដោយអនុវត្តតាមស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុកម្ពុជា ដែលក្នុងនោះរួមមាន ស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុកម្ពុជាសម្រាប់អង្គភាពមិនស្វែងរកប្រាក់ចំណេញ (CFRS for NFPEs) និង ស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុសម្រាប់សហគ្រាសធុនតូច និងមធ្យម (IFRS-SMEs)។

នៅថ្ងៃទី២៥ ខែមេសា ឆ្នាំ២០២៤ និយ័តករគណនេយ្យ និងសវនកម្មបានផ្សព្វផ្សាយសេចក្តីជូនដំណឹងលេខ ០២៣/២៤ នគស/សជណ ជូនដំណឹងអំពីការអនុម័តស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិលេខ ១៨ (IFRS No.18) ដែលអនុម័តដោយក្រុមប្រឹក្សាស្តង់ដារគណនេយ្យអន្តរជាតិ។ ស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិលេខ១៨ នឹងជំនួសស្តង់ដារគណនេយ្យអន្តរជាតិលេខ១ "ការបង្ហាញរបាយការណ៍ហិរញ្ញវត្ថុ" នឹងដាក់ដំណើរការអនុវត្តចាប់ពីថ្ងៃទី ១ ខែមករា ឆ្នាំ ២០២៧ ខាងមុខនេះ។



www.ccc-cambodia.org
info@ccc-cambodia.org
T +855 (0)23 214 152
F +855 (0)23 216 009
#9-11, Street 476,
Toul Tompoung 1, Chamkamorn
P.O. Box 885, Phnom Penh,
Cambodia

ម្ចាស់សហគ្រាស និងអង្គភាពមិនស្វែងរកប្រាក់ចំណេញនៅកម្ពុជាត្រូវបានណែនាំឱ្យត្រៀមខ្លួនសម្រាប់ការអនុវត្តស្តង់ដារថ្មីនេះ និងលើកទឹកចិត្តឱ្យមានការអនុវត្តស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិលេខ ១៨ (IFRS No.18) មុនកាលកំណត់ផងដែរ។

ដោយសារស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិលេខ ១៨ គឺជាស្តង់ដារថ្មីសម្រាប់ប្រទេសកម្ពុជា ដែលអង្គភាពមិនស្វែងរកប្រាក់ចំណេញចាំបាច់ត្រូវធ្វើការស្វែងយល់អំពីស្តង់ដារនោះ ពិសេសយល់ដឹងអំពីគោលការណ៍ណែនាំនៃការអនុវត្តសម្រាប់អង្គភាពមិនស្វែងរកប្រាក់ចំណេញសុទ្ធសាធ និងអង្គភាពមិនស្វែងរកប្រាក់ចំណេញមានអាជីវកម្មសង្គម ដើម្បីត្រៀមខ្លួនមុនពេលកាលបរិច្ឆេទនៃការអនុវត្តនៅឆ្នាំ ២០២៧ ខាងមុខនេះ។

## ២. គោលបំណង

សិក្ខាសាលាផ្សព្វផ្សាយស្តីពី « **កាតព្វកិច្ចគណនេយ្យនិងសវនកម្ម សម្រាប់អង្គភាពមិនស្វែងរកប្រាក់ចំណេញ និង ស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិលេខ ១៨**» រៀបចំឡើងក្នុងគោលបំណងសំខាន់ៗដូចខាងក្រោមនេះ៖

- បង្កើនការយល់ដឹងរបស់ សមាគម និងអង្គការមិនមែនរដ្ឋាភិបាលស្តីពីកាតព្វកិច្ចគណនេយ្យ និងសវនកម្ម និងក្របខណ្ឌគតិយុត្តិនានា ជាពិសេសសម្រាប់ស្ថាប័នដែលបានចុះបញ្ជី ឬមានបំណងចុះបញ្ជីអាជីវកម្មដាច់ដោយឡែកជាមួយអគ្គនាយកដ្ឋានពន្ធដារ។
- លើកកម្ពស់ការយល់ដឹងរបស់ សមាគម និងអង្គការមិនមែនរដ្ឋាភិបាលស្តីពីស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិលេខ ១៨ ដែលនឹងពាក់ព័ន្ធនិងប្រតិបត្តិការរបស់ខ្លួន (សម្រាប់អង្គភាពមិនរកប្រាក់ចំណេញ និងអាជីវកម្មសង្គម) នឹងរៀបចំខ្លួនសម្រាប់ការអនុវត្តប្រសិនបើវាសមស្របនឹងស្ថាប័នរបស់ខ្លួន។

## ៤. អ្នកចូលរួម

សិក្ខាសាលានេះរំពឹងនឹងមានអ្នកចូលរួមប្រមាណ ១៥០-២០០ អញ្ជើញមកពីតំណាងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក និងបរទេសជាសមាជិកនៃអង្គការ គ.ស.ក បណ្តាញអង្គការសង្គមស៊ីវិលថ្នាក់ខេត្ត អង្គការដៃគូ និងភាគីពាក់ព័ន្ធដទៃផ្សេងទៀត ដែលជាអ្នកគ្រប់គ្រងហិរញ្ញវត្ថុ, មន្ត្រីហិរញ្ញវត្ថុ, គណនេយ្យករ, និងអ្នកជំនាញដែលទទួលខុសត្រូវលើរបាយការណ៍ហិរញ្ញវត្ថុនៅក្នុងអង្គការមិនមែនរដ្ឋាភិបាល ត្រូវបានលើកទឹកចិត្ត និងអញ្ជើញឱ្យចូលរួមក្នុងសិក្ខាសាលានេះ។


www.ccc-cambodia.org
info@ccc-cambodia.org
T +855 (0)23 214 152
F +855 (0)23 216 009
#9-11, Street 476,
Toul Tompoung 1, Chamkamorn
P.O. Box 885, Phnom Penh,
Cambodia

## ៥. របៀបវារៈនៃកម្មវិធី

| ពេលវេលា | សកម្មភាព | អ្នកសម្របសម្រួល |
|---|---|---|
| ៨:០០-៨:៣០ | ចុះឈ្មោះអ្នកចូលរួម | ក្រុមការងារអង្គការ គ.ស.ក |
| ៨:៣០-៨:៤៥ | ▪ ប្រកាសហេតុ និងគោរពភ្លេងជាតិនៃព្រះរាជាណាចក្រកម្ពុជា<br>▪ ការណែនាំនៃកម្មវិធី និងគោលបំណងសិក្ខាសាលា | **អ្នកកាន់កម្មវិធី៖**<br>លោកស្រី **ប្រាក់ កែវគន្ធា**, អ្នកឯកទេសផ្នែកគោលនយោបាយ ផ្នែកច្បាប់ និងតស៊ូមតិ នៃអង្គការ គ.ស.ក |
| ៨:៤៥-៩:០០ | មតិស្វាគមន៍ | លោកស្រី **ស៊ិន ពុទ្ធារី**<br>នាយិកាប្រតិបត្តិនៃអង្គការ គ.ស.ក |
| ៩:០០-៩:២០ | សុន្ទរកថាបើកសិក្ខាសាលា | ឯកឧត្តម **ម៉ី ថារិន**<br>អគ្គនាយកនៃនិយ័តករគណនេយ្យ និងសវនកម្ម |
| ៩:២០-៩:៤០ | **សម្រាកអាហារសម្រន់** | **អ្នកចូលរួមទាំងអស់គ្នា** |
| ៩:៤០-១០:៤០ | បទបង្ហាញ និងការពិភាក្សា៖ កាតព្វកិច្ចគណនេយ្យ និងសវនកម្មសម្រាប់ NFPEs<br>▪ ការធ្វើបច្ចុប្បន្នភាពអំពីច្បាប់និងបទប្បញ្ញត្តិស្តីពីគណនេយ្យ និងសវនកម្មសម្រាប់សម្រាប់អង្គភាពមិនរកប្រាក់ចំណេញ<br>▪ តើអង្គការមិនមែនរដ្ឋាភិបាលដែលបានចុះបញ្ជីប្រាក់ចំណូលដាច់ដោយឡែកជាមួយអគ្គនាយកដ្ឋានពន្ធដារ ត្រូវធ្វើរបៀបណាដើម្បីចុះបញ្ជីនៅនិយ័តករគណនេយ្យនិងសវនកម្ម? | លោកស្រី **គួយ សេរីវឌ្ឍនា**<br>ប្រធានការិយាល័យនៃ ន.គ.ស |

| | | |
|---|---|---|
| ១០:៤០-១១:៣០ | វេទិកាពិភាក្សាជាក្រុម៖ ដោះស្រាយសំណួរ និងកង្វល់របស់អ្នកចូលរួម<br>▪ បើកម្មវិធី សំណួរ-ចម្លើយ<br>▪ បូកសរុប និងបិទកម្មវិធី | **សម្របសម្រួលដោយ:**<br>លោកស្រី **លុយ ឆារី** ប្រធានកម្មវិធី នៃអង្គការគ.ស.ក<br>**វាគ្មិន:**<br>▪ លោកស្រី **គួយ សេរីវឌ្ឍនា** ប្រធានការិយាល័យនៃ ន.គ.ស<br>▪ លោក **ពេជ សុភាចារ** មន្ត្រីបច្ចេកទេស នៃ ន.គ.ស. |
| ១១:៣០-១២:០០ | ទិដ្ឋភាពទូទៅនៃស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិលេខ១៨ និងសារៈសំខាន់នៃការអនុវត្ត សម្រាប់អង្គការសង្គមស៊ីវិលនៅកម្ពុជា | តំណាងនិយ័តករគណនេយ្យនិងសវនកម្ម |
| ១២:០០-១:៣០ | សម្រាកអាហារថ្ងៃត្រង់ | អ្នកចូលរួមទាំងអស់គ្នា |

**សម្គាល់៖ សិក្ខាសាលានេះនឹងរៀបចំឡើងជាភាសាខ្មែរ** ក្រុមការងារសូមរក្សាសិទ្ធិកែប្រែកម្មវិធីនេះក្នុងករណីចាំបាច់។

រូបភាព និងមតិយោបល់សំខាន់ៗនានានឹងត្រូវបាន ដកស្រង់ និងចែករំលែកជាសាធារណៈតាមរយៈប្រព័ន្ធផ្សព្វផ្សាយសង្គម និងគេហទំព័ររបស់ក្រុមការងារអ្នករៀបចំកម្មវិធី។ http://www.ccc-cambodia.org/en/resources/event-archives www.facebook.com/CCCsince1990 www.youtube.com/CCCambodia



www.ccc-cambodia.org
info@ccc-cambodia.org
T +855 (0)23 214 152
F +855 (0)23 216 009

#9-11, Street 476,
Toul Tompoung 1, Chamkamorn
P.O. Box 885, Phnom Penh,
Cambodia